# សេចក្ដីថ្លែងការណ៍រួម ស្ដីពី
# បញ្ហា និងការព្រួយបារម្ភ
# ពីផលប៉ះពាល់ធ្ងន់ធ្ងរទាក់ទងនឹងអភិបាលកិច្ចធនធានធម្មជាតិ

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤

យើងជាតំណាងសហគមន៍មកពីខេត្ត បាត់ដំបង កំពង់ស្ពឺ បន្ទាយមានជ័យ ពោធិសាត់ រតនៈគីរី មណ្ឌលគីរី ព្រះវិហារ កោះកុង ស្ទឹងត្រែង កំពង់ធំ កំពង់ឆ្នាំង ព្រះសីហនុ ស្វាយរៀង កំពត ក្រចេះ ព្រៃវែង កណ្ដាល ភ្នំពេញ និងអង្គការសង្គមស៊ីវិលរួមមាន សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC) វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ(API) គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា(CHRAC) សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូល ធនធាន (CRRT) ស្ម័គ្រចិត្តដើម្បីសង្គម(CVS) អង្គការអភិវឌ្ឍន៍និងភាពជាដៃគូរក្នុង សកម្មភាព (DPA) អង្គការយេនឌ័រនិងការអភិវឌ្ឍន៍ដើម្បីកម្ពុជា(GAD/C) ក្រុមការងារពិសេសសិទ្ធិ លំនៅឋាន (HRTF) អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច(ICSO) អង្គការយុវជនខ្មែរនិងការអភិវឌ្ឍន៍ សង្គម (KYSD) អង្គការជីវិតថ្លៃថ្នូរ(LWD) អង្គការស្ដារកម្ពុជា(Star Kampuchea) វេទិកានៃ អង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា (The NGO Forum on Cambodia) អង្គការវីជីឡែន (Vigilance) អង្គការទស្សនៈពិភពលោក (WVC) អង្គការ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន(YRDP) អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD) និងអង្គការសង្គមស៊ីវិលផ្សេងៗ ប្រមាណ៣៥៥នាក់នៅកម្ពុជា សូមធ្វើសេចក្ដីថ្លែងការណ៍រួមគ្នាមួយចេញពីបញ្ហាក្នុងសន្និសីទតស៊ូមតិថ្នាក់ជាតិប្រចាំឆ្នាំ លើកទី៨ស្ដីពី "**ធ្វើការរួមគ្នាដើម្បីជម្រុញកំណែ ទម្រង់លើអភិបាលកិច្ចដីធ្លី និងធនធាន ធម្មជាតិ ប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា**" ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារអ៊ិមភើរៀល និងហ្គាឌិន រាជធានីភ្នំពេញ។

យើងជាសហគមន៍ និងអង្គការសង្គមស៊ីវិល មកពីខេត្តទាំងអស់ខាងលើនៅកម្ពុជាសូមធ្វើ ការកោតសរសើរចំពោះការខិតខំរបស់រាជរដ្ឋាភិបាល ដើម្បីជម្រុញកំណែទម្រង់អភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា។ សន្និសីទតស៊ូមតិថ្នាក់ជាតិប្រចាំឆ្នាំលើក ទី៨ សូមលើកឡើងនូវបញ្ហាដែលជាការព្រួយបារម្ភ និងអនុសាសន៍ពាក់ព័ន្ធនឹងផលបះពាល់ធ្ងន់ធ្ងរមួយចំនួនដូចខាងក្រោម៖

## ១) បញ្ហាជនជាតិដើមភាគតិច និងសម្បទានដីសេដ្ឋកិច្ច

### បញ្ហាប្រឈម

ការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច មានដំណើរការស្មុគស្មាញ និងត្រូវប្រើរយៈពេលយូរ ដែលជាហេតុបណ្តាលអោយសហគមន៍ជួបបញ្ហាប្រឈមនឹងការបាត់បង់ដីធ្លី និងធនធានធម្មជាតិ តាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច និងការឈូសឆាយពីសំណាក់ក្រុមហ៊ុន និងអ្នកមានអំណាច។ មិនតែប៉ុណ្ណោះ ព្រៃបំរុងទុក ព្រៃកប់ខ្មោច ព្រៃអារក្ស ព្រៃជំនឿ ក៏ត្រូវរង់ការឈូសឆាយ និងកាប់បំផ្លាញយ៉ាងសន្ធឹកសន្ធាប់ផងដែរ។ ម្យ៉ាងវិញទៀត ការវាស់ដីកម្មសិទ្ធឯកជនជាន់គ្នា តាមរយៈការអនុវត្តបទបញ្ជា០១ ដោយមិនមានការផ្សព្វផ្សាយអោយបានទូលំទូលាយលើនីតិវិធី ដែលធ្វើអោយរាំងស្ទះដល់ដំណើរការចុះបញ្ជីដីសមូហភាព និងការរៀបចំសហគមន៍ព្រៃឈើ និងព្រៃតំបន់ការពារ។

លើសពីនេះទៅទៀត តំបន់ព្រៃការពារ ព្រៃសហគមន៍ រួមទាំងដីចំការវិលជុំជនជាតិដើមភាគតិចដែលបានបោះបង្គោលនិងកំណត់ព្រំរួចហើយ ក៏នៅតែទទួលរងនូវការឈូសឆាយដីព្រៃ ការកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់ និងរំលោភបំពានពីសំណាក់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងអ្នកមានអំណាច បើទោះបីជាពួកគាត់មានការទាមទារទៅអាជ្ញាធរថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ រួមទាំងព្រឹទ្ធសភា រដ្ឋសភា និងតុលាការ ក៏នៅតែគ្មានដំណោះស្រាយដ៏ដែល។

### សទ្ធិផលរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់ក្នុងដំណើរការចុះបញ្ជីដីសមូហភាព យោងតាមលិខិតបទដ្ឋានគតិយុតដែលមានស្រាប់ដូចជា៖ គោលនយោបាយចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច គោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច ក្នុងការបង្កើតក្រុមការងារបច្ចេកទេសដូចជា៖ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងតាមរយៈកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល និងដៃគូរអភិវឌ្ឍន៍។ ជាពិសេសនាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានចេញសេចក្តីប្រកាសអន្តរក្រសួងស្តីពី «**ការពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច**» ដែលមានក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ជាសេនាធិការដ្ឋានក្នុងការពង្រឹងការអនុវត្តបទប្បញ្ញត្តិ និងបច្ចេកទេសនានា ដែលទាក់ទងនឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យគម្រោងទាំងអស់ជានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។ ជាក់ស្តែងគណៈកម្មការអន្តរក្រសួងបានដកហូតដីសម្បទានសេដ្ឋកិច្ចដែលមិនបានអនុវត្តត្រឹមត្រូវតាមច្បាប់ចំនួន ១៩គម្រោង ក្នុងចំណោម ៣០១គម្រោង គិតត្រឹមខែតុលា ឆ្នាំ២០១៤[1] លើផ្ទៃដីសរុបប្រមាណ ២.២៨៩.៤៩០ ហិចតា។លើសពីនេះទៅទៀតរាជរដ្ឋាភិបាលក៏បានផ្តោតការយកចិត្តទុកដាក់ផងដែរនូវការពង្រាងច្បាប់ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងគោលនយោបាយ សៀវភៅសរ ក្នុងគោលបំណងជម្រុញការអនុវត្តការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែការអនុវត្តជាក់ស្តែងកន្លងមកដោយផ្អែកលើបទដ្ឋានច្បាប់ និងយន្តការដែលមាន

[1] គេហទំព័រ ទិន្នន័យពីការអភិវឌ្ឍ (http://www.opendevelopmentcambodia.net/company-profiles/economic-land-concessions/)

ស្រាប់នៅពុំទាន់មានប្រសិទ្ធភាព និងអាចឆ្លើយតបតម្រូវការដាក់ស្តែងរបស់សហគមន៍ដែលកំពុងជួបប្រទះនូវបញ្ហាវិវាទប្រឈមធ្ងន់ធ្ងរនៃវិវាទដីធ្លីដែលគំរាមកំហែងដល់សុវត្ថិភាពដីធ្លីរបស់ពួកគាត់។ តួយ៉ាងសហគមន៍បានដាក់ពាក្យបណ្តឹងទៅធានាគារពិភពលោក ស្វែករកយន្តការសម្របសម្រួលអំពីដីដែលមានទំនាស់ជាមួយសហគមន៍ ជាលទ្ធផលគឺក្រុមហ៊ុនបញ្ឈប់ការឈូសឆាយជាបណ្តោះអាសន្ន។ សហគមន៍ផ្សេងទៀតបានដាក់បណ្តឹងតាំងពីថ្នាក់មូលដ្ឋាន ដល់ថ្នាក់ជាតិ តុលាការ រដ្ឋសភា ព្រឹទ្ធសភា រួមទាំងការពាំនាំដល់ស្ថាប័នអន្តរជាតិ ប៉ុន្តែមិនទាន់ទទួលបាននូវដំណោះស្រាយនៅឡើយទេ។

## អនុសាសន៍

### សំរាប់រាជរដ្ឋាភិបាលៈ

១. សូមអោយរាជរដ្ឋាភិបាលជួយពន្លឿនការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិចទាំង ១៥ខេត្ត និងព្រៃសហគមន៍អោយបានឆាប់ ។

២. សូមអោយរាជរដ្ឋាភិបាលដកអាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនណាដែលមិនគោរពកិច្ចសន្យា។

៣. មុនការផ្តល់សម្បទានដីដល់ក្រុមហ៊ុន រាជរដ្ឋាភិបាលត្រូវសិក្សាពីផលប៉ះពាល់បរិស្ថាន ពិគ្រោះយោបល់អោយបានពេញលេញ និងមានការព្រមព្រៀងជាមុន ដើម្បីជៀសវាងទំនាស់ព្រំដីជាមួយសហគមន៍។

៤. សូមអោយរាជរដ្ឋាភិបាលបញ្ឈប់ការចាប់តំណាង និងការគំរាមកំហែងសហគមន៍ក្នុងការតវ៉ាលើបញ្ហាដីធ្លី និងព្រៃឈើ។

៥. សូមអោយរាជរដ្ឋាភិបាលពង្រឹងនូវការអនុវត្តច្បាប់ ដោយចាត់វិធានការ គោរព ការពារ និងផ្តល់ដំណោះស្រាយសមស្របដល់សហគមន៍រងផលប៉ះពាល់។

៦. គណៈកម្មការអន្តរក្រសួងបន្តផ្សព្វផ្សាយអោយបានទូលំទូលាយ នូវប្រកាសអន្តរក្រសួង និងពង្រឹងការសហការជាមួយសហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិលដើម្បីផ្តល់ព័ត៌មាន និងចូលរួមពិនិត្យ តាមដាន វាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច។

៧. គណៈកម្មការអន្តរក្រសួងឈរលើគោលការណ៍អព្យាក្រឹត្យលើកកម្ពស់សិទ្ធិជនជាតិដើមភាគតិចក្នុងធ្វើការវិនិច្ឆ័យប្រកបដោយតម្លាភាព លើផលប៉ះពាល់ដីប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ដូចជាដីព្រៃកប់ខ្មោច ដីព្រៃអារក្ស ដីព្រៃបំរុងទុក ជាមួយក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច ដើម្បីដកដីពីក្រុមហ៊ុនជូនប្រជាពលរដ្ឋ។

៨. គណៈកម្មការអន្តរក្រសួងគួរបន្ថែមការត្រួតពិនិត្យរាល់ការដឹកឈើ និងកាប់ឈើខុសច្បាប់ពីតំបន់ផ្សេងៗនាំចូលមកទីតាំងក្រុមហ៊ុន។

៩. គណៈកម្មការអន្តរក្រសួងគួរកំណត់សមាសភាពស្ថាប័នថ្នាក់ក្រោមជាតិអោយបានច្បាស់ ដើម្បីឲ្យប្រជាពលរដ្ឋងាយស្រួលទំនាក់ទំនង និងរាយការណ៍អំពីករណីប្រឈមផ្សេងៗ។ជាពិសេសកំណត់ពេលវេលាឆ្លើយតបឲ្យបានច្បាស់លាស់ និងសម្រុះសម្រួលបន្ទាន់ពីបញ្ហារបស់ប្រជាពលរដ្ឋ និងក្រុមហ៊ុន។

១០. តាមរយៈយន្តការអន្តរក្រសួងក្នុងការត្រួតពិនិត្យលើសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលគួរផ្តល់

អាទិភាពក្នុងការត្រួតពិនិត្យនៅតំបន់ដែលកំពុងមានជម្លោះរវាងសហគមន៍ជនជាតិដើមភាគតិច និងតំបន់ព្រៃសហគមន៍ដែលកំពុងស្ថិតនៅក្នុងដំណើរការចុះបញ្ជីដែលអាច ជំរុញអោយបាននូវសិទ្ធិ ក្នុងការគ្រប់គ្រងធនធានព្រៃឈើ។

**សំរាប់សង្គមស៊ីវិល និងដៃគូរអភិវឌ្ឍន៍:**

១. សូមអោយម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលបន្តការគាំទ្រផ្នែកច្បាប់អោយបានទូលំទូលាយនៅពេលសហគមន៍ប្រឈមបញ្ហាដីធ្លី និងធនធានធម្មជាតិ។

២. សូមអោយម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលបង្កើនកញ្ចប់ថវិកា ដើម្បីជួយសហគមន៍ក្នុងការទប់ស្កាត់ការឈ្លូសឆាយដីធ្លី និងបទល្មើសព្រៃឈើ។

៣. ម្ចាស់ជំនួយគួរគាំទ្រទៅលើការបង្កើនសមត្ថភាពរបស់សហគមន៍មូលដ្ឋានទៅបច្ចេកទេសតាមដានលើធនធានព្រៃឈើ ព្រមទាំងផ្តោតលើការលើកកម្ពស់វិស័យអេកូទេសចរណ៍នៅតំបន់ដែលមានសក្តានុពុលធនធានធម្មជាតិ។

## ២) **វិស័យឧស្សាហកម្មនិស្សារណកម្ម**

**បញ្ហាប្រឈម**

ឧស្សាហកម្មនិស្សារណកម្ម ជាវិស័យមួយដែលរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ និងអាចទទួលបានប្រាក់ ចំណូលដ៏សំខាន់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ បច្ចុប្បន្ន ក្របខណ្ឌច្បាប់និងបច្ចេកទេសនៅ មាន កម្រិតដែលបណ្តាលឲ្យមានការលំបាកក្នុងការគ្រប់គ្រងវិស័យនេះ ព្រមទាំងថវិកា ដែលទទួលបានពីការ ទាញយករ៉ែ ប្រេង និងឧស្ម័ននៅក្នុងប្រទេសកម្ពុជា។ ដោយឡែកទោះបីជាវិស័យនេះស្ថិតនៅក្នុង ដំណាក់កាលរុករកក៏ដោយ វាបាននិងកំពុងបង្កផលប៉ះពាល់ជាអវិជ្ជមាន ទៅដល់សហគមន៍មូលដ្ឋាន និងបរិស្ថាន ដូចជាការប្រើប្រាស់សារធាតុគីមី ដែលប៉ះពាល់គុណភាពទឹក-ដីសុខភាព មនុស្សនិង សត្វផងដែរ។ សហគមន៍មិនបានទទួលព័ត៌មានគ្រប់គ្រាន់និង ការពិគ្រោះយោបល់ពេញលេញមុននឹងមានការធ្វើសេចក្តីសម្រេចចិត្តលើគម្រោងរុករកនិងអភិវឌ្ឍន៍ធនធាន រ៉ែ ដែលធ្វើឲ្យតំបន់រុករករ៉ែ ស្ថិតនៅចំ (ត្រួតស៊ីគ្នា) តំបន់ព្រៃសហគមន៍ ដីបំរុងទុក ដីចំការរបស់សហគមន៍ ជាពិសេសតំបន់ជន ជាតិដើមភាគតិច។ ដោយសារតែព័ត៌មានពីអាជ្ញាប័ណ្ណរុករករ៉ែមិនបានផ្សព្វផ្សាយដល់សហគមន៍ បញ្ហាការរំលោភសិទ្ធិមនុស្ស ការគំរាមកំហែង ជាបញ្ហាដែលសហគមន៍កំពុងតែជួបប្រទះនិងជាបញ្ហាប្រឈម។ ក្រុមហ៊ុន អាចធ្វើសកម្មភាពរុករករ៉ែមិនស្របច្បាប់ ខណៈពេលដែលក្រុមហ៊ុនមិនមានអាជ្ញាប័ណ្ណ។ បញ្ហានេះក៏ប៉ះពាល់ដល់ជីវភាពរស់នៅរបស់សហគមន៍ដោយពួកគាត់មិនអាចចូល ទៅប្រមូលយកអនុផល ព្រៃឈើ ពីព្រៃសហគមន៍ដែលនៅក្បែរតំបន់រុករករ៉ែ។

## សន្និដ្ឋានផលរបស់រាជរដ្ឋាភិបាល

រដ្ឋាភិបាលកំពុងធ្វើសេចក្តីព្រាងច្បាប់មួយចំនួន ដើម្បីគ្រប់គ្រងវិស័យឧស្សាហកម្មនិស្សារណកម្ម។ សេចក្តីព្រាងច្បាប់អាចជម្រុញការចូលរួមនិងការពិគ្រោះយោបល់ ជាមួយសហគមន៍ទទួលរងផលប៉ះពាល់ពីវិស័យនេះ។ ស្របគ្នានេះដែរក៏បានជម្រុញឲ្យមានការកសាងហេដ្ឋារចនាសម្ព័ន្ធមួយចំនួននៅក្បែរនិងនៅតំបន់អាជីវកម្មរ៉ែ។ សហគមន៍ក៏បានទទួលសំណងមួយចំនួនតូចលើផលប៉ះពាល់ដែលបណ្តាលមកពីអាជីវកម្មរ៉ែ។ប៉ុន្តែការទទួលបានព័ត៌មាននិងកិច្ចអន្តរាគមន៍នៅថ្នាក់មូលដ្ឋាននៅមានកម្រិតនៅឡើយ។

## អនុសាសន៍

### សំរាប់រាជរដ្ឋាភិបាល

១. មុនពេលផ្តល់អាជ្ញាប័ណ្ណរុករកនិងអាជីវកម្មរ៉ែដល់ក្រុមហ៊ុន
  - ១.១ ត្រូវអនុវត្តគោលការណ៍ព្រមព្រៀងដោយសេរី ជាមុននិងទទួលបានព័ត៌មាន (FPIC)
  - ១.២ ពង្រឹងការចូលរួមយ៉ាងពេញលេញពីសាធារណៈជន ក្នុងដំណើរការការវាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន (EIA) និងមានការផ្សព្វផ្សាយរបាយការណ៍ EIA ជាមុនយ៉ាងតិចរយៈពេល ១ខែ មុននឹងអនុម័តលើរបាយការណ៍

២. ចំពោះតំបន់និងកន្លែងទីសក្ការៈរបស់ជនជាតិដើមភាគតិចមិនត្រូវផ្តល់អាជ្ញាប័ណ្ណរុករកនិងអាជីវកម្មរ៉ែ

៣. លុបចោល ដកហូតអាជ្ញាប័ណ្ណរុករករ៉ែ ចំពោះតំបន់ណាដែលសកម្មភាពរុករករ៉ែបង្កផលប៉ះពាល់ដល់សហគមន៍និង បរិស្ថាន

៤. បើកចំហរ និងផ្សព្វផ្សាយព័ត៌មានទាំងឡាយណាដែលទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ធនធានរ៉ែដល់សហគមន៍ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

៥. ពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធ និងតាមដានសកម្មភាពរុករកនិងអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន

៦. បង្កើតឲ្យមានមូលនិធិដែលបានមកពីវិស័យរ៉ែ និងប្រេង សម្រាប់កូនចៅជំនាន់ក្រោយ

៧. មានការពិគ្រោះយោបល់ជាសាធារណៈលើគោលការណ៍និងសេចក្តីព្រាងច្បាប់មួយចំនួនទាក់ទងនឹងវិស័យនេះ។

### សំរាប់វិស័យឯកជន

១. មានការពិគ្រោះយោបល់ជាមួយសហគមន៍ទទួលរងផលប៉ះពាល់ដោយអនុវត្តគោលការណ៍ FPIC

២. ត្រូវមានវិធានការឆ្លើយតបទៅនឹងផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីសកម្មភាពរុករក (ឧ. លុបរណ្តៅរ៉ែក្រោយពីបញ្ចប់សកម្មភាពរុករក)

៣. បើកចំហព័ត៌មានពីប្រតិបត្តិការ និងផែនការសកម្មភាពទៅដល់សហគមន៍

៤. ត្រូវអនុវត្តផែនការគ្រប់គ្រងនិងការពារបរិស្ថាននិងសង្គមឲ្យបានច្បាស់

**សំរាប់វិស័យឯកជន**

១. បន្តគាំទ្រថវិកា និងកសាងសមត្ថភាពបច្ចេកទេស ក្របខណ្ឌច្បាប់ដែលទាក់ទងនឹងវិស័យ ឧស្សាហកម្មនិស្សារណកម្ម

២. សម្របសម្រួលយន្តការពហុភាគី ក្នុងការដោះស្រាយផលប៉ះពាល់លើសហគមន៍

## ៣) បញ្ហាទំនប់វារីអគ្គីសនី

### បញ្ហាប្រឈម

វិស័យទំនប់វារីអគ្គីសនីនៅប្រទេសកម្ពុជា គឺជាវិស័យមួយដែលរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងធ្វើការអភិវឌ្ឍដើម្បីជាតំរូវការដល់ប្រជាពលរដ្ឋ និងជាប្រាក់ចំណូលដើម្បីធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ ប៉ុន្តែកម្ពុជានៅមិនទាន់បានត្រៀមខ្លួនដើម្បីធ្វើការអភិវឌ្ឍន៍វិស័យនេះឲ្យបានពេញលេញនៅឡើយ។ តាមការសង្កេតឃើញថាការអនុវត្តច្បាប់ នៅកម្ពុជានៅមានកម្រិតនៅឡើយ ដែល បណ្តាលឲ្យវិស័យមួយនេះ មានការលំបាកក្នុងការគ្រប់គ្រងថវិកាដ៏ច្រើនសន្ធឹកសន្ធាប់នេះ។ ផ្ទុយទៅគម្រោងសាងសង់វារីអគ្គីសនី បានបណ្តាលឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរជាអវិជ្ជមាន ទៅ លើបរិស្ថាន សង្គម វប្បធម៌ និងដីព្រៃសហគមន៍ជនជាតិដើមភាគតិច តាមរយៈការកាប់បំផ្លាញព្រៃឈើ ជីកយករ៉ែជាមួយនិងការបាត់បង់ គុណភាពទឹក និងដីកសិកម្ម សុខភាពមនុស្ស និងសត្វ។ ព្រៃឈើត្រូវបានកាប់បំផ្លាញទាំងក្នុង និងក្រៅបាតអាងនៃគម្រោងដែលនាំឲ្យបាត់បង់ជំរកសត្វព្រៃ[2]។ ការបាត់បង់លំនៅឋាន ដីស្រែចំការ[3]តាមរយៈបានរឹបអូសយ៉ាងអយុត្តិធម៌។ ជាងនេះទៅទៀតរាល់ គម្រោងទាំងអស់សហគមន៍មិនបានទទួលព័ត៌មាន និងចូលរួមពិគ្រោះយោបល់ពេញលេញជាមុននោះទេដើម្បីធ្វើសេចក្តីសំរេចចិត្តក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ ដែលហេតុនាំឲ្យមាន ការរំលោភសិទ្ធិមនុស្ស និងជម្លៀសដោយបង្ខំ។

### សមិទ្ធិផលរបស់រាជរដ្ឋាភិបាល

ដើម្បីឆ្លើយតបនឹងបញ្ហាទំនប់វារីអគ្គីសនី រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើសេចក្តីព្រៀង ច្បាប់មួយចំនួនដូចជាសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុផលប៉ះបរិស្ថាន ។ល។ ក្នុងនោះដែររដ្ឋសភាក៏បានអញ្ជើញរដ្ឋមន្ត្រីដើម្បីធ្វើការស្រាយបំភ្លឺពាក់ព័ន្ធនឹងការអនុវត្តគម្រោងវារីអគ្គីសនី[4] ។

---

[2] សត្វក្រពើភ្នំ និងត្រីនាគនៅតំបន់អារ៉ែង

[3] គម្រោងវារីអគ្គីសនីសេសានក្រោម២

[4] គម្រោងវារីអគ្គីសនីសេសានក្រោម២

**អនុសាសន៍**

*សំរាប់រាជរដ្ឋាភិបាល*

១. ពង្រឹង និងពិនិត្យមើលការអភិវឌ្ឍរបស់ក្រុមហ៊ុនវិនិយោគដើម្បីធានាថាពួកគេគោរពច្បាប់ និងគោលការណ៍ផ្សេងៗ

២. ត្រូវធានាថាដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានត្រូវមានការចូលរួមពេញលេញពីសាធារណៈជនជាពិសេសសហគមន៍រងផលប៉ះពាល់ពីគម្រោង ។

៣. បញ្ឈប់រាល់គម្រោងទាំងឡាយណាដែលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងសង្គម។

៤. ត្រូវធានាព័ត៌មានត្រូវបានផ្សព្វផ្សាយទូលាយ និងជាព័ត៌មានពិតដល់សហគមន៍រងផលប៉ះពាល់ពីគម្រោង និងគោរពសិទ្ធិមនុស្ស។

## ៤) ការបណ្តេញចេញដោយបង្ខំ ការតាំងទីលំនៅដ្ឋានថ្មី និងវិវាទដីធ្លី

**បញ្ហាប្រឈម**

បច្ចុប្បន្ន ប្រជាពលរដ្ឋនៅតែបន្តរងទុក្ខវេទនាដោយសារការបណ្តេញចេញពីគម្រោងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាដូចជាជីវភាពរបស់ប្រជាពលរដ្ឋមានស្ថានភាពយ៉ាប់យឺនជាងមុនពេលអភិវឌ្ឍន៍ ដោយសារការបណ្តាញចេញដោយបង្ខំ ខ្វះការពិគ្រោះយោបល់ជាសាធារណៈឲ្យបានត្រឹមត្រូវមុនការអនុវត្តគម្រោង គ្មានសំណងសមរម្យ និង អយុត្តិធម៌។ ការបណ្តេញដោយបង្ខំ នាំឲ្យឈានទៅដល់ការបាត់បង់ដីធ្លី លំនៅឋាន បាត់បង់មុខរបរប្រចាំថ្ងៃបាត់បង់ទ្រព្យសម្បត្តិ ជាហេតុដែលនាំអោយប៉ះពាល់ផ្លូវចិត្តដល់ក្រុមគ្រួសាររងគ្រោះ និងអនាគតកូន ហើយទីបំផុតនឹងធ្វើឲ្យប្រជាពលរដ្ឋធ្លាក់ក្នុងភាពក្រីក្រ។ ជាងនេះទៀត បញ្ហាតាំងទីលំនៅថ្មី ប្រជាពលរដ្ឋជួបផលលំបាកក្នុង ការទទួលសេវាសាធារណៈដូចជា៖ ការប្រើប្រាស់ទឹកស្អាត ផ្លូវថ្នល់ ផ្សារ សាលារៀន និងមន្ទីរពេទ្យ។ល។ កង្វះការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់ទូលំទូលាយជាមួយប្រជាពលរដ្ឋ អំពីគម្រោងផែនការអភិវឌ្ឍន៍ភាគច្រើនរបស់រាជរដ្ឋាភិបាល នាំឲ្យប្រជាពលរដ្ឋក្លាយ ជាជនរងគ្រោះដូចជាការ រំលោភសិទ្ធិមនុស្សជាពិសេសកុមារ និងស្ត្រី និងមិនទទួលបានការដោះស្រាយសមរម្យពីគម្រោងការអភិវឌ្ឍទាំងនោះ។ ម្យ៉ាងទៀតយើងក៏សង្កេតឃើញថា រាល់សកម្មភាពបណ្តេញចេញដោយបង្ខំ អាជ្ញាធរមានសមត្ថកិច្ចតែងតែប្រើអំពើហឹង្សា និងការគំរាមកំហែង ដោយប្រើកំលាំងប្រដាប់អាវុធ រហូតមានការចាប់ខ្លួនបញ្ជូនទៅតុលាការ និងដាក់ឃុំឃាំង កាត់ទោសដោយអយុត្តិធម៌។ អ្នកដែលប្រព្រឹត្តិបទល្មើសមិនត្រូវបាននាំខ្លួនទៅផ្តន្ទាទោសតាមច្បាប់ទេ។ ចំណែកឯការដោះស្រាយសំណងទៀតសោត មិនបានធ្វើឲ្យមានការពេញចិត្តពីសំណាក់ប្រជាពលរដ្ឋភាគច្រើនទេ ប៉ុន្តែគេត្រូវតែបង្ខំចិត្តចាកចេញពីលំនៅឋានចាស់ទៅកាន់ទីតាំងថ្មីតាមការសម្រេចចិត្តរបស់អាជ្ញាធរ និងក្រុមហ៊ុនវិនិយោគដោយមិនមានសំណងសមរម្យ ហើយអ្នកខ្លះរងនូវការរើសអើងពីអាជ្ញាធរក្នុងពេលដោះស្រាយសំណង ដូចជាអាជ្ញាធរមិនមានការទទួលខុសត្រូវក្នុងការអនុវត្តកាតព្វកិច្ចការពារសិទ្ធិប្រជាពលរដ្ឋដែលជា ហេតុនាំឲ្យប្រជាពលរដ្ឋបាត់បង់ជំនឿទុកចិត្តចំពោះអាជ្ញាធរមានសមត្ថកិច្ច។ ជាមួយនេះគ្នាដែរយន្តការដោះស្រាយ

វិវាទដីធ្លីដែលនៅជាធរមានមិនបានអនុវត្តឲ្យមានប្រសិទ្ធិភាពហើយអាជ្ញាធរតែងតែគេចវេសពីបញ្ហាទាំងនោះ នៅឡើយទេដូចជាប្រជាពលរដ្ឋនៅបន្ត ឡើងមកដាក់ញ្ញាតកាន់តែច្រើន ឡើងដូចជាសហគមន៍ឡពាង កំពង់ឆ្នាំង យុវញ្ញៀនឌីវីឡុបមិនគ្រុប កោះកុង សហគមន៍ប្រមេ ព្រះវិហារ ថ្មដាពោធិសាត់ បឹងកក់ បុរីកីឡា ភ្នំពេញ ។ល។

## សមិទ្ធផលរបស់រាជរដ្ឋាភិបាល

ទន្ទឹងនឹងបញ្ហាប្រឈមខាងដើម្បីពន្លឿនការដោះស្រាយវិវាទដីធ្លី យើងក៏បានកត់សំគាល់ឃើញថារាជរដ្ឋាភិបាលបានខឹតខំប្រឹងប្រែងបង្កើត និង អនុម័តគោលនយោបាយមួយចំនួនដូចជា គោលនយោបាយដីធ្លី"សៀវភៅសរ" គោលនយោយបាយជាតិលំនៅឋាន គោលនយោបាយវាយតម្លៃថ្លៃអចលនាវត្ថុ ។ល។ លើសពីនោះទៀតព្រះរាជាណាចក្រកម្ពុជាបានប្រកាសដាក់ចេញនូវ គោលនយោបាយចាស់ សម្មកភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាលនូវកម្មវិធីថ្មីមួយដែល ត្រូវអនុវត្តន៍ដោយក្រុមយុវជនស្ម័គ្រចិត្ត ជាអ្នកជួយចុះវាស់កំណត់ព្រំប្រទល់ដីជូនប្រជាពលរដ្ឋនៅ៣តំបន់ ដូចជាដីសម្បទានដីការដេកហូត និងព្រៃសម្បទាន។ គណៈកម្មការរបស់រដ្ឋសភា និងព្រឹទ្ធសភាបានចុះពិនិត្យ និងអញ្ជើញអ្នកព័ន្ធដល់កន្លែងដែលមានវិវាទសម្រាប់ក្នុងរបៀបវារៈដោះស្រាយ។ រាជរដ្ឋាភិបាលក៏បានបើកកិច្ចសហការទូលាយចំពោះសង្គមស៊ីវិលជាជំនួយការក្នុងការដោះស្រាយវិវាទដីធ្លី ឧទាហរណ៍ប្រជុំប្រចាំត្រីមាស និងប្រជុំក្រុមបច្ចេកទេសដីធ្លីជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## អនុសាសន៍

### សំរាប់រាជរដ្ឋាភិបាល

១. ចុះបញ្ជីដីធ្លីជាប្រព័ន្ធសម្រាប់សហគមន៏ក្រីក្រនៅតាមបណ្ដាខេត្ត ក្រុង រាជធានី និងពន្លឿនការផ្ដល់កម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋនៅទាំងអស់ទូទាំងប្រទេស។
២. ត្រូវផ្សព្វផ្សាយ និងពិគ្រោះយោបល់ឲ្យបានទូលំទូលាយអំពីគំរោងអភិវឌ្ឍន៍នានាជាមួយប្រជាពលរដ្ឋជាពិសេសសហគមន៍ដែលរស់នៅក្នុងតំបន់រងផលប៉ះពាល់មុននឹង ផ្ដល់ការអនុញ្ញាតិឲ្យក្រុមហ៊ុនវិនិយោគ។
៣. រាល់ការអភិវឌ្ឍត្រូវអោយមានផលប្រយោជន៏ដល់ពលរដ្ឋនៅនឹងកន្លែងដែលត្រូវអភិវឌ្ឍន៍។
៤. ជានាប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ ហើយគោរពសិទ្ធិមនុស្ស និងបញ្ឈប់ប្រើប្រាស់ប្រព័ន្ធតុលាការមកគាបសង្កត់មកលើប្រជាពលរដ្ឋដែលទាមទារសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋានរបស់ខ្លួន។
៥. បញ្ឈប់ការបណ្ដេញចេញដោយបង្ខំ ប៉ុន្ដែត្រូវធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង។
៦. ដោះលែងជាបន្ទាន់ប្រជាពលរដ្ឋដែលតវ៉ាទាមទារសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានចេញពីពន្ធនាគារ។
៧. បញ្ឈប់ការរារាំងសកម្មភាពអហឹង្សារបស់ប្រជាពលរដ្ឋរងគ្រោះ ឧទាហរណ៍ ការដាក់ញត្តិ សំណូមពរផ្សេងៗទៀត។
៨. បញ្ឈប់ការចោទប្រកាន់អង្គការសង្គមស៊ីវិលថាជាអ្នកញុះញង់នៅពីក្រោយប្រជាពលរដ្ឋ

សំរាប់ម្ចាស់ជំនួយ

១. ជួយបន្តការគាំទ្រពល់គម្រោង និងសកម្មភាពដោះស្រាយទៅលើបញ្ហាទំនាស់ដីធ្លី និងលំនៅឋាន ប្រកបដោយប្រសិទ្ធភាព។

២. បន្តសហការជាមួយរាជរដ្ឋាភិបាលក្នុងការចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងជម្រុញឲ្យរាជរដ្ឋាភិបាល បន្តដោះស្រាយសំណូមពរ និងអនុសាសន៍ផ្សេងៗរបស់ប្រជាពលរដ្ឋរងគ្រោះ។

## ៥) សិទ្ធិទទួលព័ត៌មាន

### បញ្ហាប្រឈម

ក្នុងពេលបច្ចុប្បន្ននេះ កម្ពុជានៅមិនទាន់មានវប្បធម៌បើកចំហរព័ត៌មានទូលំទូលាយនៅឡើយ។ រាជរដ្ឋាភិបាលនៅមានភាពខ្វះចន្លោះ ឬស្ទាក់ស្ទើរក្នុងការបើកចំហ ឬ ផ្សព្វផ្សាយព័ត៌មានសាធារណៈ ដោយមូលហេតុមួយចំនួន រួមមានៈ កង្វះខាតធនធាន សមត្ថភាពមានកម្រិត និងភាពមិនច្បាស់លាស់អំពីអ្វីដែលចាត់ទុកថាជាព័ត៌មានសម្ងាត់ជាដើម បើទោះបីជាមានមូលដ្ឋានច្បាប់មួយចំនួនដែលបានកំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋ ក្នុងការបើកចំហ ឬ ផ្សព្វផ្សាយព័ត៌មានសាធារណៈក៏ដោយ។ ការមិនបញ្ចេញព័ត៌មានជាសាធរណៈ ទោះបីដោយមូលហេតុសមត្ថភាពរបស់ស្ថាប័នរដ្ឋនៅមានកម្រិតក្តី ដោយយន្តការសម្រាប់ការបើកចំហ ឬ ផ្សព្វផ្សាយព័ត៌មាននៅមានកង្វះខាតក្តី ឬដោយស្ថាប័នរដ្ឋមានភាព ស្ទាក់ស្ទើរក្នុងការបើកចំហ ឬ ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងបញ្ហាណាដែលរសើបក្តី តួយ៉ាងដូចជាករណីទាំងឡាយទាក់ទងនឹងដំណោះស្រាយដីសម្បទានសេដ្ឋកិច្ច គម្រោងរុករករ៉ែ និងបញ្ហាតាមរោងចក្រកាត់ដេរជាដើមទើបជារឿយៗ គេឃើញមាននូវរឿងវិវាទជាច្រើនដែលកើតចេញមកពីទំនាស់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ក៏ដូចជាវិសមភាពនៃអំណាចរវាងភាគីអ្នកក្រីក្រនៅជនបទ កម្មកររោងចក្រ និងអ្នកមានទ្រព្យសម្បត្តិ ក៏ដូចជាអ្នកមានអំណាច ផងដែរ។

ដោយមើលឃើញអំពីសារសំខាន់នៃការទទួលបានព័ត៌មាន ក្នុងការជួយទប់ស្កាត់ជម្លោះដាយថាហេតុ និងចូលរួមចំណែកលើកកម្ពស់កម្មវិធីនយោបាយកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជានោះអង្គការសង្គមស៊ីវិល និងប្រជាសហគមន៍ សូមជម្រុញឲ្យរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភានីតិកាលទី៥ បង្កើនសមត្ថភាពស្ថាប័នសាធារណៈក្នុងការបើកចំហព័ត៌មាន ដោយផ្អែកលើមូលដ្ឋានច្បាប់ដែលមានស្រាប់ផង និងអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅពេលឆាប់ៗខាងមុខនេះដោយស្របទៅ តាមបទដ្ឋាន អន្តរជាតិ ផង។

សង្គមស៊ីវិល និងប្រជាសហគមន៍បាននិងកំពុងតាមដានយ៉ាងយកចិត្តដាក់ ហើយកត់សំគាល់ថាសិទ្ធិទទួលព័ត៌មាន ឬការបើកចំហព័ត៌មាន គឺជាបញ្ហាដែលមានផលប៉ះពាល់ដល់គ្រប់វិស័យទាំងអស់ តួយ៉ាងដូចជាវិស័យសេដ្ឋកិច្ច វិនិយោគ កសិកម្ម រ៉ែ វារីអគ្គិសនី បរិស្ថាន និងអភិវឌ្ឍន៍ទីក្រុងជាដើម។ ស្ថានភាពបច្ចុប្បន្ន នៃការអនុវត្តច្បាប់ព្រៃឈើ និងដីធ្លី ក៏ដូចជាការគ្រប់គ្រងធនធានធម្មជាតិ និងសិទ្ធិមនុស្ស សុទ្ធតែទទួលរងនូវផលប៉ះពាល់ពីកង្វះការបើកចំហ ព័ត៌មាន។ សហគមន៍ជនជាតិដើមភាគតិច ដែលរស់នៅពឹងអាស្រ័យខ្លាំងជាងគេ លើដីធ្លី និង ព្រៃឈើ

កំពុងប្រឈមនឹងបញ្ហាចុះបញ្ជីដីសម្ភូហភាព និងសហគមន៍តំបន់ការពារ ក៏ដូចជាបញ្ហាសម្បទានដីសេដ្ឋកិច្ច។ បញ្ហាវិវាទដីធ្លី ក៏ជាប់ជាមួយគ្នានឹងបញ្ហាបណ្តេញចេញដោយបង្ខំផងដែរហើយបញ្ហាទាំងអស់នោះសុទ្ធតែទាក់ទងនឹងសិទ្ធិទទួលព័ត៌មាន ឬការបើកចំហព័ត៌មាន។ ដូច្នេះដំណោះស្រាយណាមួយនូវសិទ្ធិទទួលព័ត៌មាន គឺជាការរួមចំណែកដោះស្រាយនូវបញ្ហាទាំងប៉ុន្មានដែល បានរៀបរាប់ខាងលើ បើទោះបីជាមិនបានទាំងស្រុងក៏ដោយ។

## សមិទ្ធិផលរបស់រាជរដ្ឋាភិបាល

អង្គការសង្គមស៊ីវិល និងប្រជាសហគមន៍ទទួលស្គាល់ការខិតខំប្រឹងប្រែងមួយចំនួនរបស់រាជរដ្ឋាភិបាលក្នុងការលើកកំពស់សិទ្ធិទទួលព័ត៌មាន ជាពិសេសនៅថ្នាក់ក្រោមជាតិ តាមរយៈកម្មវិធីមួយចំនួនដូចជាកម្មវិធីអភិបាលកិច្ចល្អមូលដ្ឋាន ក្របខ័ណ្ឌគណនេយ្យភាពសង្គម កម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងច្រកចេញចូលតែមួយជាដើម។ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការចាប់ផ្តើមដំណើរការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ត្រូវបានកោតសរសើរ ក៏ពិតមែនហើយ ក៏ប៉ុន្តែសង្គមស៊ីវិលចង់ឲ្យរាជរដ្ឋាភិបាលធ្វើច្បាប់នេះឲ្យបានឆាប់ និងធានាថាជាច្បាប់មួយដែលល្អ។ ជាមួយគ្នានេះដែរ ក្នុងខណៈដែលច្បាប់មិនទាន់មាននោះការពង្រឹងការអនុវត្តន៍បទដ្ឋានច្បាប់ដែលមានរួចស្រាប់មកហើយ ក៏អាចរួមចំណែកបានមួយផ្នែកធំក្នុងកាត់បន្ថយ និង បញ្ចៀសបញ្ហាទាំងឡាយដែលបានរៀបរាប់ខាងលើ។ ខាងក្រោមនេះគឺជាអនុសាសន៍មួយចំនួនរបស់សង្គមស៊ីវិល និងប្រជាសហគមន៍ ជូនចំពោះរាជរដ្ឋាភិបាល។

## អនុសាសន៍

១. ក្រសួង មន្ទីរ និងអង្គភាពនានារបស់រដ្ឋ ត្រូវបើកចំហព័ត៌មានសាធារណៈ ជាពិសេស តម្លៃសេវាកម្ម នីតិវិធីក្នុងការទទួលបានសេវា និងពេលវេលាកំណត់ដោយច្បាប់

២. ពង្រឹងសមត្ថភាពស្ថាប័ន និងបង្កើតនូវយន្តការទាំងឡាយដើម្បីធានាថាប្រជាជនកម្ពុជានឹងទទួលបានព័ត៌មានពេញលេញ

៣. អនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដោយមានការចូលរួមពិគ្រោះយោបល់ឲ្យបានទូលំទូលាយ និងទទួលយកនូវអនុសាសន៍ពីស្ថាប័នសង្គមស៊ីវិលពាក់ព័ន្ធ ថែមទាំង បញ្ជាក់ឱ្យបានច្បាស់ អំពីព័ត៌មានណាដែលត្រូវរក្សាជាសម្ងាត់។

៤. បង្កើនសមត្ថភាពបុគ្គលិករាជរដ្ឋាភិបាលក្នុងការផលិត និងចែកចាយព័ត៌មាន

៥. ផ្តល់កិច្ចការពារចំពោះប្រជាពលរដ្ឋគ្រប់រូបដែលបានបង្ហាញ និងចែកចាយនូវព័ត៌មានពិតប្រាកដ ឬ ព័ត៌មានទាំងឡាយណាដែលបម្រើដល់ប្រយោជន៍សាធារណៈ

៦. ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពី សិទ្ធិទទួលបានព័ត៌មាន និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងការស្វែងរកព័ត៌មានសាធារណៈទាំងឡាយដែលពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ

៧. បង្កើតឱ្យមានបរិយាកាសអំណោយផលប្រសើរជាងមុន សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

- អ្នកស្រី វ៉េន សាមីន — សហគមន៍មកពីខេត្តកំពង់ស្ពឺ លេខទូរស័ព្ទ 097 9012 869
- លោក ក្រោស សុខ — សហគមន៍មកពីខេត្តមណ្ឌលគីរី លេខទូរស័ព្ទ 096 4203 097
- លោក សល់ សុផាត — សហគមន៍មកពីខេត្តរតនគីរី លេខទូរស័ព្ទ 097 2709 705
- លោក គល់ ចាន់នី — សហគមន៍មកពីខេត្តស្ទឹងត្រែង លេខទូរស័ព្ទ 092 509 879
- លោកស្រី សូ សុផល្លា — សហគមន៍មកពីភ្នំពេញ លេខទូរស័ព្ទ 012 702 914
- លោក ឡាត់ គី — ប្រធាន ផ្នែកដីធ្លី និងជីវភាព សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) លេខទូរស័ព្ទ 012 828 411
- លោក សួន ប៊ុនស័ក្តិ — ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) លេខទូរស័ព្ទ 092 344 357
- លោក ឡាំ សុជាតិ — នាយករង វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) លេខទូរស័ព្ទ 077 555 679
- លោក តឹក វណ្ណារ៉ា — នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia) លេខទូរស័ព្ទ 012 793 489
- លោក ម៉ម សម្បត្តិ — នាយកប្រតិបត្តិ អង្គការអភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព (DPA) លេខទូរស័ព្ទ 012 779 734
- លោកស្រី គឹម ណាតាសា — នាយករងកម្មវិធី សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធា (CRRT) លេខទូរស័ព្ទ 012 513 802
- លោក ប៉ែន សុមុន្នី — នាយកប្រតិបត្តិ អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS) លេខទូរស័ព្ទ 012 708 093
- លោក សៀ ភារម្យ — នាយកលេខាធិការដ្ឋាន ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) លេខទូរស័ព្ទ 012 852 325
- លោក សៅ វណ្ណសី — នាយកប្រតិបត្តិ អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO) លេខទូរស័ព្ទ 012 813 744
- លោក ឈួន បូរិទ្ធ — នាយកប្រតិបត្តិ អង្គការយុវជនខ្មែរនិងការអភិវឌ្ឍន៍សង្គម (KYSD) លេខទូរស័ព្ទ 012 798 488
- លោក មិន ស — នាយកប្រតិបត្តិ អង្គការជីវិតថ្ងៃថ្នូរ (LWD) លេខទូរស័ព្ទ 012 329 926
- លោកស្រី ជេត ចរិយា — នាយិកាប្រតិបត្តិ អង្គការស្តារកម្ពុជា (Star Kampuchea) លេខទូរស័ព្ទ 012 802 460
- លោក ជាង សុខា — នាយកប្រតិបត្តិ អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន(YRDP) លេខទូរស័ព្ទ 012 360 464
- លោកស្រី អេង រស្មី — តំណាងអង្គការទស្សនៈពិភពលោក (WVC) លេខទូរស័ព្ទ 011 332 335
- លោក គឹម សុវណ្ណ — នាយកប្រតិបត្តិអង្គការវីជីឡែន លេខទូរស័ព្ទ 012 957 282